## រឿងទី១០: ការស្លាប់របស់លោកស្ទេផាន

**ខគម្ពីរ៖ កិច្ចការ៧៖៥៩**

នៅពេលគេគប់ដុំថ្មសម្លាប់នោះ លោកស្ទេផានទូលអង្វរថា៖ «ព្រះអម្ចាស់យេស៊ូអើយ សូមទទួលវិញ្ញាណរបស់ទូលបង្គំផង»។

ក្រោយពីព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ ពួកសាវ័កទាំងអស់ បានខិតខំប្រឹងប្រែងដើម្បីប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់ ក៏មានមនុស្សកាន់តែច្រើនឡើងៗ ចាប់ផ្ដើមជឿព្រះយេស៊ូដែរ។ ពួកសាវ័កព្រះយេស៊ូទាំងអស់ បានជ្រើសរើសអ្នកជំនួយចំនួនប្រាំពីរនាក់ ដើម្បីធ្វើកិច្ចការនៅក្នុងក្រុមជំនុំ។ ក្នុងចំណោមពួកគេ មានមនុស្សម្នាក់ឈ្មោះថាស្ទេផាន ជាមនុស្សដែលមានជំនឿល្អ។ ឈ្មោះថាស្ទេផាន គឺមានន័យថា «មកុដ»។ ស្ទេផានបានធ្វើការអស្ចារ្យជាច្រើន។ គាត់អាចប្រោសជំងឺ និងអាចបណ្ដេញវិញ្ញាណអាក្រក់ចេញបានដូចព្រះយេស៊ូដែរ។ ធ្វើឱ្យមានមនុស្សជាច្រើនបានមករកស្ទេផាន។ ស្ទេផានបានប្រើប្រាជ្ញាញាណដែលព្រះជាម្ចាស់ប្រទានឱ្យគាត់ ពន្យល់ព្រះបន្ទូលទៅមនុស្សគ្រប់គ្នាយ៉ាង ច្បាស់ៗ។ ដូច្នេះហើយ មានមនុស្សកាន់តែច្រើនដើរតាមស្ទេផាន។

ប៉ុន្តែ មានថ្ងៃមួយ មនុស្សដែលមានចិត្តស្អប់ និងច្រណែនស្ទេផាន បាននិយាយបង្កាច់នៅចំពោះក្រុមប្រឹក្សាជាន់ខ្ពស់សាសន៍យូដាថា ស្ទេផានបានប្រមាថដល់ព្រះ និងមើលងាយដល់ព្រះបន្ទូលរបស់ព្រះអម្ចាស់ផងដែរ។ ។ ស្ទេផាន បានត្រូវគេចាប់នាំទៅក្រុមប្រឹក្សាជាន់ខ្ពស់សាសន៍យូដា។ មនុស្សម្នាដែលជុំគ្នានៅទីនោះបានសម្លឹងមើលទៅស្ទេផាន។ ប៉ុន្តែ មុខរបស់ស្ទេផានប្រែទៅដូចជាមុខរបស់ទេវតា។ នៅសម័យនោះ ពេលមានអ្នកណាម្នាក់ប្រមាថមើលងាយដល់ព្រះ និងព្រះបន្ទូលរបស់ទ្រង់ នឹងត្រូវគេគប់សម្លាប់នឹងដុំថ្ម ។ ពួកមនុស្សដែលស្អប់និងច្រណែនស្ទេផាន ពួកគេចង់ឱ្យស្ទេផានត្រូវស្លាប់ដោយការគប់នឹងដុំថ្ម។ ប៉ុន្តែ ស្ទេផានមិនខ្លាចអ្វីទាំងអស់ លោកចាប់ផ្ដើមប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងអង់អាចនៅចំពោះមុខមនុស្សគ្រប់គ្នា។ ហើយមនុស្សទាំងនោះក៏ចាប់ផ្ដើមគប់ស្ទេផាននិងដុំថ្ម។ ស្ទេផានបានលុតជង្គង់ចុះហើយអធិស្ឋាន។ «ព្រះអម្ចាស់អើយ សូមទទួលយកទូលបង្គំផង ហើយសូមទ្រង់អត់ទោសដល់ពួកមនុស្សទាំងនេះផង» ទីបំផុត ស្ទេផានបានស្លាប់។ ស្ទេផានបានប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់រហូតដល់គាត់ស្លាប់។ ស្ទេផានក្លាយជាមនុស្សដំបូងដែលថ្វាយជីវិតរបស់ខ្លួននៅក្នុងក្រុមជំនុំដំបូង។



**សកម្មភាពទី១** សូមឆ្លើយសំណួរខាងក្រោម។

a. តើស្ទេផានបានធ្វើអ្វី?

-----------------------------------------------------------------------------------------------

b. តើនរណាជាមនុស្សដំបូងគេដែលបានពលីជីវិតក្នុងក្រុមជំនុំសម័យដើម?

-----------------------------------------------------------------------------------------------

c. សូមអានកិច្ចការ ៧៖៥៤-៦០ រួចឆ្លើយសំណួរ។ តើមានបីចំណុចអ្វីខ្លះដែលស្ទេផានអធិប្បាយ ហើយត្រូវគេគប់សម្លាប់នឹងដុំថ្ម?
សូមបំពេញចន្លោះខាងក្រោម។

◈ «មើលហ្ន៎! ខ្ញុំឃើញ ________________ និងឃើញ ________________ ឈរនៅខាងស្តាំព្រះជាម្ចាស់»។

◈ ព្រះអម្ចាស់យេស៊ូអើយសូមទទួល ________________ របស់ទូលបង្គំផង!»។

◈ «ព្រះអម្ចាស់អើយ! សូមកុំ ________________ គេ ព្រោះតែ ________________ នេះធ្វើអ្វី»។

- សូមអានខគម្ពីរខាងក្រោម រួចទន្ទេញ។ (កិច្ចការ៧៖៥៩)

**នៅពេលគេគប់ដុំថ្មសម្លាប់នោះ លោកស្ទេផានទូលអង្វរថា៖ «ព្រះអម្ចាស់យេស៊ូអើយសូមទទួលវិញ្ញាណរបស់ទូលបង្គំផង»។**

**សកម្មភាពទី២** សូមស្វែងរករូបអាថ៌កំបាំង ឱ្យបាន១០។

▶ មួកណូអែល, បាល់ទះ, ដំបងបេស្បល, ផ្លែប៉ោម, អាយគូម, ពស់, ម៉ាឡេត, ម្ជុល, ខ្យងសមុទ្រ, សម

